


Photo: International Rivers

# ការខាតបង់ដ៏គួរអោយបារម្ភ៖

## ការសិក្សារបស់ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ និង ផលប៉ះពាល់នៃការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅលើដងទន្លេមេគង្គ

### ព័ត៌មានអំពីការសិក្សា

- ការសិក្សារបស់ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ ត្រូវបានធ្វើឡើង អស់រយៈពេលជាងប្រាំមួយឆ្នាំ ចាប់តាំងពីឆ្នាំ ២០១២ ដល់ ២០១៧។
- ការសិក្សានេះបង្ហាញថា ទំនប់វារីអគ្គិសនីធំៗចំនួន១១ នៅលើតួមេទន្លេមេគង្គក្រោម និងទំនប់វារីអគ្គិសនីនៅតាមដៃទន្លេមេគង្គចំនួន១២០ទៀត ដែលត្រូវបានគ្រោងសាងសង់រួចត្រឹមឆ្នាំ ២០៤០ នឹងបង្កគ្រោះថ្នាក់ដល់ប្រព័ន្ធអេកូឡូហ្ស៊ី សេដ្ឋកិច្ច និងសន្តិសុខស្បៀងនៅក្នុងតំបន់។
- ទំនប់វារីអគ្គិសនីទាំងនេះនឹងកាត់បន្ថយបរិមាណដីល្បាប់ដល់ទៅ៩៧ភាគរយ មិនឱ្យហូរដល់តំបន់ដីសណ្តទន្លេមេគង្គ។[1] ដីល្បាប់ផ្តល់ជីវជាតិ ចាក់បំពេញអាងទន្លេ ក៏ដូចជាផ្តល់អត្ថប្រយោជន៍សម្រាប់កសិកម្ម ជលផល និងគុណភាពទឹក។ ជាលទ្ធផល វាបង្កើនប្រយោជន៍សេដ្ឋកិច្ចដល់បណ្តាប្រទេសដែលស្ថិតនៅក្នុងតំបន់អាងទន្លេ។
- អាងស្តុកទឹកទំនប់នៅលើតួមេទន្លេ ហេដ្ឋារចនាសម្ព័ន្ធការពារទឹកជំនន់ និងរនាំងនានាចំពោះការបម្លាស់ទីរបស់ត្រី នឹងបង្កគ្រោះថ្នាក់ជាច្រើនដល់ប្រព័ន្ធអេកូឡូសហ្ស៊ីក្នុងតំបន់។

[1] គណៈកម្មការទន្លេមេគង្គ (MRC) របាយការណ៍តាមវិស័យស្តីអំពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាននៃការអភិវឌ្ឍថាមពលវារីអគ្គីសនី ទៅលើ ស្ថានភាពសង្គម បរិស្ថាន និងសេដ្ឋកិច្ចនៃអាងទន្លេមេគង្គក្រោម MRC ឆ្នាំ២០១៧ ទំព័រទី ១០

INTERNATIONAL RIVERS
people • water • life

- ការអភិវឌ្ឍថាមពលវារីអគ្គិសនី រហូតដល់ឆ្នាំ ២០៤០ នឹងបណ្តាលឱ្យបរិមាណធនធានជលផលធ្លាក់ចុះជាខ្លាំង។ បរិមាណធនធានជលផលសរុបនឹងថយចុះពី៣៥-៤០% ត្រឹមឆ្នាំ២០២០ និងពី៤០-៨០% ត្រឹមឆ្នាំ ២០៤០។ ភាគរយដែលនឹងបាត់បង់ធៀបនឹងបរិមាណជលផលបច្ចុប្បន្នរបស់ប្រទេសនីមួយៗគឺ៖ ថៃ ៥៥% ឡាវ ៥០% កម្ពុជា ៣៥% និងវៀតណាម ៣០%។[2]
- ការអភិវឌ្ឍថាមពលវារីអគ្គិសនី រហូតដល់ឆ្នាំ ២០៤០ នឹងបណ្តាលឱ្យបាត់បង់ពពួកត្រីបម្លាស់ទី នៅក្នុងតំបន់មួយភាគធំនៃទន្លេមេគង្គ។[3] ត្រឹមឆ្នាំ២០២០ និង២០៤០ នឹងគ្មានពពួកត្រីបម្លាស់ទីនៃទន្លេមេគង្គ ដែលអាចរស់រានមានជីវិតបានក្នុងអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនីទាំងនោះ នោះទេ។[4]
- បម្រែបម្រួលអាកាសធាតុ រួមផ្សំជាមួយនឹងការបាត់បង់ត្រី អាចបណ្តាលឱ្យមាន "អសន្តិសុខស្បៀងកម្រិតធ្ងន់ធ្ងរនៅតាមសហគមន៍ នៅប្រទេសឡាវ និងកម្ពុជា។"[5]

## តើការសិក្សារបស់ក្រុមប្រឹក្សាគឺជាអ្វី ?

ក្នុងរយៈពេល៦ឆ្នាំ ចាប់ពីឆ្នាំ២០១២ ដល់២០១៧ គណៈកម្មការទន្លេមេគង្គ (MRC) បានបញ្ចប់*ការសិក្សាស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍទន្លេមេគង្គប្រកបដោយចីរភាព ដែលរួមបញ្ចូលការសិក្សាផលប៉ះពាល់នៃគម្រោងថាមពលវារីអគ្គិសនីនានាដែលស្ថិតនៅលើតួមេទន្លេផងដែរ* ឬហៅថា ការសិក្សារបស់ក្រុមប្រឹក្សា (Council Study)។

គោលបំណងរួមនៃការសិក្សានេះគឺដើម្បីជួយឱ្យគណៈកម្មការទន្លេមេគង្គមានមូលដ្ឋានសម្រាប់ ផ្តល់យោបល់ដល់ប្រទេសជាសមាជិកដូចជា កម្ពុជា ឡាវ ថៃ និងវៀតណាម អំពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានក្នុងការអភិវឌ្ឍធនធានទឹកនៅក្នុងអាងទន្លេមេគង្គ។

ការសិក្សានេះមានគោលដៅស្វែងរកនូវភស្តុតាងបែបវិទ្យាសាស្ត្រដែលអាចទុកចិត្តបាន ដើម្បីបង្ហាញពីទិដ្ឋភាពស្តីពីផលប៉ះពាល់ទៅលើ បរិស្ថាន សង្គម និងសេដ្ឋកិច្ច ដែលអាចកើតមានបណ្តាលមកពីការអភិវឌ្ឍតាមដងទន្លេមេគង្គ។ ភស្តុតាងនេះសំដៅ កែលម្អការរៀបចំផែនការ កសាងសមត្ថភាពប្រទេសជាសមាជិក និងផ្តល់នូវវិធីទប់ស្កាត់ បង្ការ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ឬទូទាត់សំណងដល់ប្រទេសដែលរងផលប៉ះពាល់។

## តើការសិក្សារបស់ក្រុមប្រឹក្សាបានផ្តួចផ្តើមឡើងដោយរបៀបណា ?

ក្នុងដំណើរការពិគ្រោះយោបល់ជាមុន នៃទំនប់វារីអគ្គិសនីសាយ៉ាប៊ូរី (Xayaburi) រដ្ឋាភិបាលវៀតណាមបានអំពាវនាវឱ្យផ្អាកការសាងសង់ទំនប់វារីអគ្គិសនីនេះរយៈពេល១០ឆ្នាំ ដោយរងចាំការសិក្សាបន្ថែមទៀតលើសក្តានុពលនៃផលប៉ះពាល់ ឲ្យហើយរួចរាល់សិន។ ការស្នើសុំនេះអនុលោមតាម អនុសាសន៍នៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដែលសម្របសម្រួលដោយគណៈកម្មការទន្លេមេគង្គ ដោយអនុសាសន៍នោះស្នើឲ្យធ្វើការវាយតម្លៃទៅលើផលប៉ះពាល់ជាបណ្តុំ ក៏ដូចជាឱកាសនៃគម្រោងវារីអគ្គិសនីនានាដែលបានស្នើឡើង។

ក្នុងឆ្នាំ ២០១១ គណៈកម្មការទន្លេមេគង្គបានយល់ព្រមរៀបចំឱ្យមានការសិក្សារបស់ក្រុមប្រឹក្សា ដើម្បីវាយតម្លៃទៅលើអាងទន្លេទាំងមូលអំពីផលប៉ះពាល់ជាបណ្តុំនៃគម្រោងវារីអគ្គិសនីទាំងនោះ ដើម្បីផ្តល់ព័ត៌មានបន្ថែមសម្រាប់ការសម្រេចចិត្តទៅលើគម្រោងនីមួយៗ ដោយអនុលោមទៅតាម*នីតិវិធីជូនដំណឹង ពិគ្រោះយោបល់ និងព្រមព្រៀងជាមុន*។ គេសង្ឃឹមថា ការសិក្សានេះនឹងបំពេញនូវចន្លោះខ្វះខាតនៃព័ត៌មាន ផ្តល់ទិដ្ឋភាពពេញលេញសម្រាប់ការសម្រេចចិត្ត ក៏ដូចជាគាំទ្រដល់ការធ្វើផែនការដែលផ្អែកលើមូលដ្ឋានដែលដាក់បញ្ចូលនូវធាតុចូលបានគ្រប់ជ្រុងជ្រោយអំពីផលប៉ះពាល់ជាបណ្តុំទៅលើអាងទន្លេទាំងមូល។

គណៈកម្មការទន្លេមេគង្គបានទទួលមូលនិធិចំនួន ៤.៧លានដុល្លារសម្រាប់ការសិក្សានេះ ពី  ដៃគូអភិវឌ្ឍន៍នានាដែលរួមមានមកពីប្រទេស អូស្ត្រាលី បែលហ្ស៊ិក សហភាពអឺរ៉ុប ហ្វាំងឡង់ បារាំង អាល្លឺម៉ង់ ជប៉ុន លុចសំបួហ្សួ ស៊ុយអែត ស្វីស អាមេរិក និងធនាគារពិភពលោក។ ប្រទេសជាសមាជិកនៃគណៈកម្មការទន្លេមេគង្គក៏បានចូលរួមវិភាគទានផងដែរ។

## តើការសិក្សារបស់ក្រុមប្រឹក្សានេះពិនិត្យមើលលើអ្វីខ្លះ ?

ការសិក្សារបស់ក្រុមប្រឹក្សាវិភាគអំពីការអភិវឌ្ឍវិស័យថាមពលវារីអគ្គិសនីនៅក្នុងអាងទន្លេមេគង្គក៏ដូចជា វិស័យសំខាន់ៗដទៃទៀតពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានទឹក ដូចជា ធារាសាស្ត្រ កសិកម្ម ការប្រើប្រាស់ដី ការដឹកជញ្ជូន ការប្រើប្រាស់ទឹកលក្ខណៈគ្រួសារ និងឧស្សាហកម្ម ការការពារទឹកជំនន់ និងការប្រែប្រួលអាកាសធាតុ។ សេចក្តីសង្ខេបនេះផ្តោតលើលទ្ធផលនៃការសិក្សាដែលបានរកឃើញជុំវិញអំពីការអភិវឌ្ឍវិស័យថាមពលវារីអគ្គិសនី។

ការសិក្សានេះសំដៅគិតគូរលើអាងទន្លេមេគង្គទាំងមូល ប៉ុន្តែការសិក្សាអំពីផលប៉ះពាល់នៃការអភិវឌ្ឍធនធានទឹកត្រូវបានធ្វើឡើងជាពិសេសនៅច្រករបៀងសំខាន់ៗនៃទន្លេមេគង្គ រួមទាំងតំបន់ឆ្នេរផងដែរ ដែលមានបួនតំបន់៖

1. ច្រករបៀងក្នុងចំងាយ១៥គម សងខាង តាមបណ្តោយដងទន្លេមេគង្គ ពីចំនុចម្ខាងដែលចាប់ផ្តើមនៅព្រំដែនចិន និងចំនុចម្ខាងទៀតនៅខេត្តក្រចេះ (ប្រទេសកម្ពុជា)

2 គណៈកម្មការទន្លេមេគង្គ (MRC) ការសិក្សារបស់ក្រុមប្រឹក្សា៖ ការសិក្សាស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍទន្លេមេគង្គប្រកបដោយចីរភាព ដែលរួមទាំងផលប៉ះពាល់នៃគម្រោងថាមពលវារីអគ្គីសនីលើដងទន្លេមេគង្គ MRC ឆ្នាំ២០១៧

3 គណៈកម្មការទន្លេមេគង្គ (MRC) ការសិក្សារបស់ក្រុមប្រឹក្សា៖ ការវាយតម្លៃផលប៉ះពាល់នៃការវិវឌ្ឍធនធានទឹក MRC ឆ្នាំ២០១៧ ទំព័រទី iii

4 *របាយការណ៍តាមវិស័យ ២០១៧ ទំព័រទី ៦៣*

5 ការសិក្សារបស់ក្រុមប្រឹក្សា៖ ការវាយតម្លៃផលប៉ះពាល់សរុប ២០១៧ ទំព័រទី v



Riverbank garden at Pak Beng
Photo: International Rivers

2. តំបន់ទំនាបលិចទឹកនៅកម្ពុជា ដែលមាន ទន្លេសាប និងបឹងទន្លេសាប
3. តំបន់ដីសណ្តមេគង្គនៅកម្ពុជា និងវៀតណាម
4. តំបន់ឆ្នេរដែលរងឥទ្ធិពលផ្ទាល់ពីទន្លេមេគង្គ

ការសិក្សានេះវាយតម្លៃលើបរិបទសំខាន់ៗចំនួនបី សម្រាប់ការអភិវឌ្ឍធនធានទឹកនៅក្នុងអាងទន្លេ៖

1. បរិបទដំណាក់កាលដំបូង (M1) រួមមានគម្រោងអភិវឌ្ឍនានាមកដល់ត្រឹមឆ្នាំ២០០៧។
2. បរិបទអនាគតជាក់លាក់ (M2) រួមមានគម្រោងអភិវឌ្ឍទាំងអស់ដែលមានស្រាប់ កំពុងសាងសង់ និងដែលត្រូវបានរំពឹងយ៉ាងមុតមាំថានឹងបញ្ចប់នៅឆ្នាំ២០២០។
3. បរិបទផែនការអភិវឌ្ឍន៍ (M3) រួមមានគម្រោងអភិវឌ្ឍទាំងអស់ដែលមានស្រាប់ កំពុងសាងសង់ និងគម្រោងអភិវឌ្ឍដែលត្រូវបានរំពឹងថានឹងត្រូវបានបញ្ចប់នៅឆ្នាំ២០៤០ ប្រសិនបើអនុវត្តទៅតាមផែនការទាំងស្រុង ដែលរួមមានគ្រប់ទំនប់វារីអគ្គិសនីតាមដងទន្លេមេទាំងអស់ដែលបានស្នើសុំ។

នៅពេលគណៈកម្មការទន្លេមេគង្គពិនិត្យមើលការអភិវឌ្ឍដែលបានគ្រោងទុកសម្រាប់ចន្លោះឆ្នាំ ២០២០ និង២០៤០ គេបានគិតគូរ និងរំពឹងទុកថាអាកាសធាតុនឹងកាន់តែក្តៅ និងសើមជាងមុន ហើយមនុស្សនឹងពង្រីកការតាំងទីលំនៅទៅក្នុងតំបន់ទំនាបលិចទឹក។

## លទ្ធផលដែលបានរកឃើញសំខាន់ៗនៃការសិក្សារបស់ក្រុមប្រឹក្សា

**ការសិក្សានេះបង្ហាញថា ទំនប់វារីអគ្គិសនីធំៗចំនួន១១ នៅលើតួមេទន្លេមេគង្គក្រោម និងទំនប់វារីអគ្គិសនីនៅតាមដៃទន្លេចំនួន១២០ ដែលបានគ្រោងទុកសម្រាប់ឆ្នាំ២០៤០ បង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន និងសេដ្ឋកិច្ចក្នុងតំបន់ ព្រមទាំងលទ្ធភាពក្នុងការទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់របស់ប្រជាជនក្នុងតំបន់។**

គេព្យាករណ៍ថា ការអភិវឌ្ឍធនធានទឹកជាបន្តបន្ទាប់រហូតដល់ឆ្នាំ២០៤០ នឹងបង្កអតុល្យភាពធ្ងន់ធ្ងរ ដោយបង្កឱ្យមានការខូចបង់ដល់វិស័យណាមួយក្នុងចំណោមវិស័យ ទឹក ស្បៀងអាហារ និងថាមពល។[6] ប្រសិនបើទិន្នផលត្រី និងផលិតភាពកសិកម្មធ្លាក់ចុះ ស្បៀងអាហារនឹងកាន់តែខ្វះខាត ចំណែកតម្លៃរបស់វានឹងកើនឡើង។ ជាលទ្ធផល ប្រជាជនក្នុងតំបន់នឹងត្រូវបានរុញឱ្យធ្លាក់ចូលទៅក្នុងភាពក្រីក្រ ហើយតំបន់អាងទន្លេមេគង្គក្រោមមួយភាគធំនឹងកាន់តែងាយរងគ្រោះដោយសារស្ថានភាពអាកាសធាតុ។

សក្តានុពលអនាគតរបស់បណ្តាប្រទេសជាសមាជិកនៃគណៈកម្មការទន្លេមេគង្គពឹងអាស្រ័យលើធនធានធម្មជាតិ ជាពិសេស ដី ព្រៃឈើ និងជលផល។ គេព្យាករណ៍ថា គ្រាន់តែគិតត្រឹមផលប៉ះពាល់នៃគម្រោងអភិវឌ្ឍទាំងអស់ដែលបានគ្រោងសង់ឲ្យរួចរាល់ត្រឹមរយៈពេលមធ្យម ( ២០២០ ) ធនធានធម្មជាតិអាចនឹងធ្លាក់ចុះរហូតដល់ជិត៤០ភាគរយ នៃផលិតផលសរុបក្នុងស្រុក (GDP) ឆ្នាំ២០១៧ នៃតំបន់អាងទន្លេមេគង្គក្រោម។[7]

6 *ការសិក្សារបស់ក្រុមប្រឹក្សា៖ លទ្ធផលសំខាន់ៗ ២០១៧ ទំព័រទី ១*
7 *ឯកសារយោងដូចខាងលើ*

**សរុបមក "ផែនការអភិវឌ្ឍនៃគម្រោងទាំងអស់ដែលបូកបញ្ចូលគ្នាគិតត្រឹមសំរាប់ឆ្នាំ២០២០ និងត្រឹមឆ្នាំ២០៤០ ទំនងជាបង្កឱ្យមានការធ្លាក់ចុះនូវភាពធន់ទ្រាំ បង្កើនភាពងាយរងគ្រោះ និងប៉ះពាល់ដល់និរន្តភាពនៃសហគមន៍ក្នុងតំបន់អាងទន្លេមេគង្គក្រោម... ជាពិសេសក្រុមគ្រួសារក្រីក្រគឺជាក្រុមដែលងាយរងការលំបាកជាងគេបំផុតចំពោះផលប៉ះពាល់ទាំងនោះ។"[8]**

ខាងក្រោមគឺជាចំណុចសំខាន់ៗដកស្រង់ពីការសិក្សារបស់ក្រុមប្រឹក្សា អំពីផលប៉ះពាល់នៃការអភិវឌ្ឍធនធានទឹកនៅលើដងទន្លេមេគង្គ៖

## ដីល្បាប់

**គម្រោងថាមពលវារីអគ្គិសនីបច្ចុប្បន្ន នឹងកាត់បន្ថយលំហូរដីល្បាប់រហូតដល់៩៧ភាគរយ មិនឱ្យហូរដល់ដំបន់ដីសណ្តរទន្លេមេគង្គ។[9]**

ដីល្បាប់បង្កើនជីវជាតិ ក៏ដូចជាចាក់បំពេញអាងទន្លទាំងមូល និងមានមុខងារសំខាន់ៗជាច្រើនទៀតនៅក្នុងប្រព័ន្ធអេកូឡូហ្ស៊ីសម្រាប់វិស័យ កសិកម្ម ជលផល រុក្ខជាតិ និងសត្វក្នុងទឹក និងគុណភាពទឹក ដែលជាកត្តាគាំទ្រដល់សេដ្ឋកិច្ចរបស់ប្រទេសជាសមាជិកក្នុងតំបន់។

ការបាត់បង់ដីល្បាប់ និងជីវជាតិ ដោយសារទំនប់វារីអគ្គិសនីនៅខ្សែទឹកខាងលើ នឹងបង្កឱ្យគុណភាពជីវជាតិដី ទិន្នផលស្រូវ និងត្រីធ្លាក់ចុះជាខ្លាំង។[10] ការសិក្សាបញ្ជាក់ថា៖ "នៅពេលដែលទិន្នផលត្រី និងស្រូវធ្លាក់ចុះក្នុងពេលទន្ទឹមគ្នា នោះវានឹងបង្កើតឲ្យមានសក្តានុពលខ្ពស់ក្នុងការបង្កឱ្យមានការខ្វះខាតអាហារូបត្ថម្ភនៅតាមក្រុមគ្រួសាររបស់ប្រជាពលរដ្ឋ។"[11]

ប្រជាជនតាមជនបទក្នុងតំបន់អាងទន្លេមេគង្គដែលមានជីវភាពពឹងផ្អែកលើទន្លេសម្រាប់ជាប្រព័ន្ធផ្គត់ផ្គង់ទឹក ជីវជាតិដី ធនធាននេសាទ ឬផលិតផលធម្មជាតិផ្សេងៗ នឹងទទួលរងផលប៉ះពាល់យ៉ាងខ្លាំង ដោយការបាត់បង់ដីល្បាប់ ដែលបង្កដោយការរាំងរបស់ទំនប់វារីអគ្គិសនីនានាដែលស្ថិតនៅខ្សែទឹកខាងលើ។ តំបន់ងាយរងគ្រោះបំផុតគឺ ប្រព័ន្ធអេកូឡូហ្ស៊ីរបស់តំបន់ទំនាបលិចទឹក និងទន្លេសាបនៅប្រទេសកម្ពុជា និងតំបន់ដីសណ្តមេគង្គនៅវៀតណាម។[12]

ការសឹករិចរឹល ការបាក់ច្រាំងទន្លេ និងបាតទន្លេ នឹងកើនឡើងយ៉ាងខ្លាំង ដោយសារតែការបាត់បង់ដីល្បាប់ និងបម្រែបម្រួលកម្រិតទឹក ក្នុងអាងទន្លេផ្នែកខាងក្រោម ជាពិសេសនៅតំបន់ដីសណ្តមេគង្គនៅវៀតណាម និងតំបន់មួយចំនួននៅតាមដងទន្លេមេគង្គ ចាប់តាំងពីទីក្រុងវៀងច័ន្ទដល់ខេត្តស្ទឹងត្រែង។[13]

## ផលប៉ះពាល់ចំពោះប្រព័ន្ធអេកូឡូហ្ស៊ី

**គេព្យាករណ៍ថា ផលប៉ះពាល់ឆ្លងដែននៃគម្រោងអភិវឌ្ឍធនធានទឹករហូតដល់ឆ្នាំ២០៤០ នឹងបង្កឱ្យមាន "ការខូចខាតយ៉ាងធំធេងទៅលើប្រព័ន្ធអេកូឡូហ្ស៊ីទាំងមូល"។[14]**

ផលប៉ះពាល់ជាប្រព័ន្ធនៃទំនប់វារីអគ្គិសនីដែលស្ថិតនៅលើតួមេទន្លេ គឺមានដូចជា ការរាំងខ្ទប់ដីល្បាប់ រំខានផ្លូវបម្លាស់ទី ប៉ះពាល់លំហូរទឹក ដែលផលប៉ះពាល់ទាំងនេះមាន "កម្រិតធំ និងវិសាលភាពទូលំទូលាយ ហើយក៏ប៉ះពាល់យ៉ាងធំធេងដល់គម្រោងអភិវឌ្ឍធនធានទឹកដទៃដែលបានគ្រោងទុកនៅក្នុងតំបន់អាងទន្លេមេគង្គក្រោម"។[15]

គម្រោងថាមពលវារីអគ្គិសនីនៅតាមតំបន់អាងទន្លេមេគង្គនឹងកាត់បន្ថយលំហូរទឹករដូវវស្សា ហើយបង្កើនលំហូរទឹករដូវប្រាំង ក្នុងលក្ខខណ្ឌធម្មតា (មិនមែនក្នុងលក្ខខណ្ឌអាកាសធាតុធ្ងន់ធ្ងរ)។ ចរន្តផ្លាស់ប្តូរនេះ អាចនឹងជួយកាត់បន្ថយគ្រោះទឹកជំនន់ ប៉ុន្តែវានឹងបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ប្រព័ន្ធអេកូឡូហ្ស៊ីរបស់សត្វ និងរុក្ខជាតិតាមដងទន្លេ ចីរភាព និងលទ្ធភាពក្នុងការស្វែងរកត្រីដើម្បីចិញ្ចឹមជីវិតរបស់ប្រជាជនក្នុងតំបន់។

ក្រៅពីនេះ នៅមានផលប៉ះពាល់អវិជ្ជមានផ្សេងៗទៀតចំពោះប្រព័ន្ធអេកូឡូហ្ស៊ីដែលអាចនឹងបង្កឡើងដោយសារអាងស្តុកទឹកវារីអគ្គិសនីដែលស្ថិតនៅលើតួមេទន្លេ ហេដ្ឋារចនាសម្ព័ន្ធការពារទឹកជំនន់ និងរនាំងនានាដែលជាឧបសគ្គរារាំងការបម្លាស់ទីរបស់ត្រី។ អាងស្តុកទឹកទាំងនោះត្រូវបានគេរំពឹងគិតថា វានឹងស្រូបយកទឹកមួយភាគធំពីទន្លេមេគង្គ រួចបម្លែងខ្លួនទៅជាទីជម្រកបឹងដ៏ជ្រៅមួយ ពីត្រឹមទន្លេឈាងសាននៅប្រទេសថៃ រហូតដល់ខេត្តក្រចេះនៅប្រទេសកម្ពុជា លើកលែងតែតំបន់ក្នុងចន្លោះពីវៀងច័ន្ទ ទៅប៉ាកសេ នៅប្រទេសឡាវ។ ទីជម្រកបឹងជ្រៅបែបនេះមិនសមស្របសម្រាប់អំបូរសត្វជាច្រើនដែលរស់នៅតាមទន្លេមេគង្គនោះទេ ប៉ុន្តែវាសមស្របសម្រាប់សិប្បិសត្វ (ពពួកជំពូកលៀសគ្រុំ) កង្កែប និងខ្យង។[16]

សំណឹករិចរឹល ការបាក់ច្រាំងទន្លេដែលបណ្តាលមកពីផលប៉ះពាល់ឆ្លងដែននឹងមានកំណើនយ៉ាងឆាប់រហ័ស នៅពេលទំនប់វារីអគ្គិសនីនានាក្នុងអាងទន្លេមេគង្គក្រោមត្រូវបានសាងសង់រួចរាល់។ សំណឹករិចរឹល ការបាក់ច្រាំងទន្លេជាច្រើនអាចនឹងកើតឡើងនៅក្នុងគ្រប់តំបន់ទាំងអស់ នៃអាងទន្លេមេគង្គក្រោម ជាពិសេសតំបន់ដីសណ្តទន្លេមេគង្គ។[17]

គេនឹងត្រូវចំណាយប្រាក់ដល់ទៅ ៦ពាន់លានដុល្លា ($6 billion) ដើម្បីការពារច្រាំងទន្លេដែលប្រឈមនឹងសំណឹករិចរឹល ការបាក់ច្រាំងទន្លេ។ ហានិភ័យទឹកជំនន់ និងសក្តានុពលនៃការខូចខាតមានកំណើន៥ទៅ១០ដង ពីព្រោះដោយសារតម្លៃទំនិញកើនឡើងក្នុងពេលដែលសេដ្ឋកិច្ចកាន់តែមានកំណើនកាន់តែខ្ពស់ ជាពិសេសនៅតំបន់ទីក្រុង ដែលប្រឈមជាមួយនឹងហានិភ័យខ្ពស់។[18]

ថ្វីបើទំនប់ដែលគ្រប់គ្រងបានល្អអាចបង្កើនផលិតភាពកសិកម្មដោយកាត់បន្ថយហានិភ័យនៃទឹកជំនន់ និងគ្រោះរាំងស្ងួតក៏ដោយ វាក៏នឹងកាត់បន្ថយលំហូរទឹកទន្លេមេគង្គ រីឯកំណើនទឹកសមុទ្រនឹងកើនឡើង ដែលនឹងបង្កើនកម្រិតទឹកប្រៃក្នុងទឹកសាប ហើយនិងបង្កឱ្យបាត់បង់ទិន្នផលស្រូវនៅតំបន់ដីសណ្តទន្លេមេគង្គ។[19]

## ផលប៉ះពាល់លើធនធានជលផល និងសន្តិសុខស្បៀង

**ការអភិវឌ្ឍថាមពលវារីអគ្គិសនីរហូតដល់ឆ្នាំ២០៤០ នឹងបង្កឱ្យបរិមាណត្រីធ្លាក់ចុះយ៉ាងខ្លាំង។ បរិមាណត្រីសរុបនឹងធ្លាក់ចុះពី ៣៥-៤០% ត្រឹមឆ្នាំ២០២០ និង៤០-៨០% ត្រឹមឆ្នាំ ២០៤០។**

8 *ការសិក្សារបស់ក្រុមប្រឹក្សា៖ ការវាយតម្លៃផលប៉ះពាល់សរុប ២០១៧ ទំព័រទី iv–v*
9 *របាយការណ៍តាមវិស័យ ២០១៧ ទំព័រទី១០*
10 *ការសិក្សារបស់ក្រុមប្រឹក្សា៖ លទ្ធផលសំខាន់ៗ ២០១៧ ទំព័រទី ២*
11 *ឯកសារយោងដូចខាងលើ ទំព័រទី ១*
12 *ឯកសារយោងដូចខាងលើ ទំព័រទី ២*
13 *ឯកសារយោងដូចខាងលើ*
14 *ការសិក្សារបស់ក្រុមប្រឹក្សា៖ ការវាយតម្លៃផលប៉ះពាល់សរុប ២០១៧ ទំព័រទី iii*
15 *ការសិក្សារបស់ក្រុមប្រឹក្សា៖ លទ្ធផលសំខាន់ៗ ២០១៧ ទំព័រទី ២*
16 *ឯកសារយោងដូចខាងលើ*
17 *ការសិក្សារបស់ក្រុមប្រឹក្សា៖ ការវាយតម្លៃផលប៉ះពាល់សរុប ២០១៧ ទំព័រទី iii*
18 *ការសិក្សារបស់ក្រុមប្រឹក្សា៖ លទ្ធផលសំខាន់ៗ ២០១៧ ទំព័រទី ៣*
19 *ឯកសារយោងដូចខាងលើ*



Mekong Delta, Vietnam
Photo: International Rivers

**ប្រទេសនីមួយៗនឹងបាត់បង់ធនធានជលផលក្នុងបរិមាណ៖ ថៃ ៥៥% ឡាវ ៥០% កម្ពុជា ៣៥% និងវៀតណាម ៣០%។[20]**

**ការអភិវឌ្ឍទំនប់វារីអគ្គិសនីរហូតដល់ឆ្នាំ២០៤០ នឹងកាត់បន្ថយប្រភេទត្រីបម្លាស់ទី មួយចំណែកធំនៃទន្លេមេគង្គ។[21] ត្រឹមឆ្នាំ ២០២០ និង២០៤០ នឹងគ្មានពពួកត្រីបម្លាស់ទី អាចរស់រានមានជីវិតនៅក្នុងអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនីបាននោះទេ។[22]**

នៅពេលដែលអាងស្តុកទឹកនៃទំនប់ត្រូវបានសាងសង់រួច នោះវានឹងរារាំងមិនឱ្យពងនិងកូនត្រីរសាត់ចុះតាមលំហូរទឹកទៅកាន់ខ្សែខាងក្រោម ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វដ្តនៃការពងកូនរបស់ប្រភេទត្រីបម្លាស់ទី។ ក្រៅពីនេះ ត្រីធំៗដែលអាចបម្លាស់ទីចុះក្រោមបានក៏ងាយប្រឈមនឹងអត្រាគ្រោះថ្នាក់និងស្លាប់ខ្ពស់ ដោយសារទួប៊ីនរបស់វារីអគ្គិសនី។ ការសិក្សាបង្ហាញថា៖ “ប្រភេទត្រីបម្លាស់ទី ធំៗមួយចំនួនអាចនឹងផុតពូជ ហើយបរិមាណជីវម៉ាសត្រីនឹងអាចបាត់បង់រហូតដល់ទៅ៦០% ក្នុងតំបន់ល្បាក់ទំនប់”។[23]

**ការប្រែប្រួលអាកាសធាតុ រួមជាមួយនឹងការបាត់បង់ត្រីដែលជាប្រភពប្រូតេអ៊ីនដ៏សំខាន់មួយ ទំនងជាបង្កឱ្យមាន “អសន្តិសុខស្បៀងកម្រិតធ្ងន់ធ្ងរនៅតាមសហគមន៍នៅក្នុងប្រទេសឡាវ និងកម្ពុជា”។[24]**

20 *ឯកសារយោងដូចខាងលើ*
21 *ការសិក្សារបស់ក្រុមប្រឹក្សា៖ ការវាយតម្លៃផលប៉ះពាល់សរុប ២០១៧ ទំព័រទី iii*
22 *របាយការណ៍តាមវិស័យ ២០១៧ ទំព័រទី ៦៣*
23 *ឯកសារយោងដូចខាងលើ ទំព័រទី ៦៧*
24 *ការសិក្សារបស់ក្រុមប្រឹក្សា៖ ការវាយតម្លៃផលប៉ះពាល់សរុប ២០១៧ ទំព័រទី v*

## ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច

យោងទៅតាមការសិក្សារបស់ក្រុមប្រឹក្សា “ផែនការអភិវឌ្ឍបច្ចុប្បន្នធ្វើការវិនិយោគលើសលប់ទៅលើវិស័យកសិកម្ម និងវារីអគ្គិសនី នៅក្នុងកម្រិតមួយដែលបង្កការវិនាសដល់វិស័យសន្តិសុខស្បៀង។ ការវិនិយោគនេះអាចនឹងមានផលប៉ះពាល់អវិជ្ជមានទៅលើកំណើនផលិតផលក្នុងស្រុកសរុប(GDP Growth) នៃប្រទេសដែលជាសមាជិកនៃអាងទន្លេមេគង្គក្រោម។”[25]

ការចែករំលែកផលចំនេញ និងការខាតបង់ នៃការអភិវឌ្ឍថាមពលវារីអគ្គិសនីពុំមានភាពស្មើគ្នានៅទូទាំងតំបន់អាងទន្លេមេគង្គក្រោមទេ ហើយក៏មិនប្រាកដថាផលប្រយោជន៍នឹងបានទៅដល់ប្រទេសជាម្ចាស់ដែរ។[26] ប្រាក់ចំណូលភាគច្រើនពីថាមពលវារីអគ្គិសនីនឹងហូរចូលទៅក្រុមហ៊ុន និងធនាគារបរទេស។

ទំនប់ថាមពលវារីអគ្គិសនីនឹងផ្តល់ប្រយោជន៍ក្នុងកម្រិតខុសៗគ្នាដល់បណ្តាប្រទេសសមាជិក ទាំងបួនរបស់គណៈកម្មការទន្លេមេគង្គ។ ប្រទេសថៃគឺជាប្រទេសដែលនឹងទទួលបានផលប្រយោជន៍ចម្បងជាងគេមកពីទំនប់វារីអគ្គិសនីដែលស្ថិតនៅលើតួមេទន្លេ នៅប្រទេសឡាវ ចំណែកប្រទេសវៀតណាមគឺជាប្រទេសទទួលផលចម្បង ពីទំនប់វារីអគ្គិសនីដែលស្ថិតនៅលើតួមេទន្លេនៅប្រទេសកម្ពុជា នេះបើយោងតាមផែនការនាំចូលថាមពលដែលបានគ្រោងទុក។[27]

25 *ការសិក្សារបស់ក្រុមប្រឹក្សា៖ លទ្ធផលសំខាន់ៗ ២០១៧ ទំព័រទី ២*
26 *ឯកសារយោងដូចខាងលើ*
27 *របាយការណ៍តាមវិស័យ ២០១៧ ទំព័រទី ៦*

យោងតាមទស្សនៈម៉ាក្រូសេដ្ឋកិច្ច ផលប្រយោជន៍សេដ្ឋកិច្ចភាគច្រើនដែលទទួលបានពីទំនប់ថាមពលវារីអគ្គិសនីដែលស្ថិតនៅលើតួមេទន្លេ នឹងបានដល់ប្រទេសវិនិយោគទុននៅក្រៅតំបន់អាងទន្លេមេគង្គក្រោម ដូចជាប្រទេសចិន ម៉ាឡេស៊ី និងកូរ៉េខាងត្បូង។[28] ចំណែកអ្នកទទួលរងផលប៉ះពាល់ ខាតបង់ចម្បងជាងគេគឺសហគមន៍ដែលពឹងផ្អែកលើការនេសាទ និងការធ្វើកសិកម្មតាមបណ្តោយច្រករបៀងទន្លេមេគង្គ។

## បម្រែបម្រួលអាកាសធាតុ

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍធនធានទឹកមានទំនាក់ទំនងគ្នាយ៉ាងខ្លាំង។ ទំនាក់ទំនងនេះមានភាពស្មុគស្មាញយ៉ាងខ្លាំង និងត្រូវការឲ្យមានការវិភាគចម្រុះវិស័យ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលបានគូសបញ្ជាក់នៅក្នុងការសិក្សារបស់ក្រុមប្រឹក្សារួមមាន ការកើនឡើងកំណើនកម្ពស់ទឹកសមុទ្រ ការជន់លិច និងកំណើនទឹកប្រៃជ្រៀតចូលទៅក្នុងតំបន់ដីសណ្តទន្លេមេគង្គនៅប្រទេសវៀតណាម និងភាពងាយរងគ្រោះដល់សត្វ និងរុក្ខជាតិមួយចំនួននៅតាមដងទន្លេ។[29]

ការប្រែប្រួលអាកាសធាតុទំនងជានឹងបង្កើនផលប៉ះពាល់អវិជ្ជមានរបស់គម្រោងថាមពលវារីអគ្គិសនី។ បម្រែបម្រួលអាកាសធាតុបង្កហានិភ័យធំធេងចំពោះសន្តិសុខស្បៀង និងកំណើនសេដ្ឋកិច្ច ជាពិសេសប្រសិនបើលក្ខខណ្ឌរាំងស្ងួតនឹងកើតមានឡើងពិតមែន។[30]

យោងទៅតាមការសិក្សារបស់ក្រុមប្រឹក្សា លក្ខខណ្ឌអាកាសធាតុរាំងស្ងួតនឹងកាត់បន្ថយផលចំណេញដែលនឹងទទួលបានពីថាមពលវារីអគ្គិសនីរហូតដល់ ២.២ ពាន់លានដុល្លារ ($2.2 billion) ក្នុងអត្រាតម្លៃបច្ចុប្បន្នសរុប និងបង្កការបាត់បង់ធនធានជលផលប្រហែល ១៥ភាគរយ។[31] ឥទ្ធិពលរួមគ្នានៃការវិនិយោគលើសលប់លើវិស័យកសិកម្ម និងថាមពលវារីអគ្គិសនី និងការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ អាចធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពរបស់បណ្តាប្រទេសតាមអាងទន្លេមេគង្គក្រោម ក្នុងការធ្វើឲ្យស្ថានភាពប្រទេសរបស់ខ្លួនកាន់តែក្រីក្រ ឬរក្សានូវស្ថានភាពរបស់ខ្លួនក្នុងនាមជាប្រទេសដែលមានចំណូលកម្រិតទាប ឬមធ្យម។

## បទអត្ថាធិប្បាយ មតិស្ថាបនា៖ គម្លាតនៃការវិភាគ និងការទទួលយកលទ្ធផល

ក្រៅពីមានការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រឆ្នាំ២០១០ និងអនុសាសន៍ឱ្យមានការវាយតម្លៃលម្អិតបន្ថែមទៅលើផលប៉ះពាល់ ការសិក្សារបស់ក្រុមប្រឹក្សាបានបង្ហាញយ៉ាងច្បាស់ថា ផលប៉ះពាល់នៃទំនប់ទាំងនេះ នឹងផ្តល់ផលវិបាកធ្ងន់ធ្ងរដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងសេដ្ឋកិច្ចរបស់បណ្តាប្រទេសក្នុងតំបន់ទន្លេមេគង្គ។

នៅមានចម្ងល់សំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងវិធីសាស្ត្ររបស់ការសិក្សា និងការទទួលយកអនុសាសន៍ទៅអនុវត្តដោយរដ្ឋាភិបាលរបស់ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ។ ឧទាហរណ៍ មានភាពមិនស៊ីសង្វាក់គ្នាជាច្រើនរវាងលទ្ធផលសិក្សារបស់ក្រុមប្រឹក្សា និងរបាយការណ៍របស់គណៈកម្មការទន្លេមេគង្គ និងពុំមានការវាយតម្លៃអំពីការខាតបង់ជាទឹកប្រាក់ដោយសារការបាត់បង់ដីល្បាប់។ ដោយសារកង្វះខាតទាំងនេះ ការសិក្សានេះអាចនឹងមិនទាន់វាយតម្លៃគ្រប់ជ្រុងជ្រោយទៅលើផលប៉ះពាល់ទាំងស្រុងនៃគម្រោងថាមពលវារីអគ្គិសនី ទៅលើប្រជាជន និងសេដ្ឋកិច្ចនៅតាមតំបន់អាងទន្លេមេគង្គក្រោមនៅឡើយទេ។

## កង្វះខាតទិន្នន័យអំពីផលប៉ះពាល់ចំពោះស្ត្រី

ទន្លេមេគង្គផ្តល់នូវប្រភពប្រូតេអ៊ីនដល់ទៅ៨០ភាគរយ នៃតម្រូវការរបស់ប្រជាជនក្នុងតំបន់។ ស្ត្រីគឺជាអ្នកទទួលខុសត្រូវចម្បងក្នុងការរៀបចំផ្តល់អាហារដល់ក្រុមគ្រួសារ និងស្វែងរកទឹកមកប្រើប្រាស់នៅផ្ទះ។ ការសិក្សារបស់ក្រុមប្រឹក្សាកត់សម្គាល់ថា "បញ្ហាយេនឌ័រមានទំនាក់ទំនងជាមួយនឹងការអភិវឌ្ឍធនធានទឹក ពីព្រោះស្ត្រីងាយរងគ្រោះជាងបុរសនៅពេលមានទឹកជំនន់ និងគ្រោះរាំងស្ងួត ដោយសារតែស្ត្រីពឹងផ្អែកច្រើនលើធនធានធម្មជាតិ ហើយឧបសគ្គសង្គមកំហិតសមត្ថភាពសម្របខ្លួនរបស់ពួកគេ។"[32] ទោះជាមានការកត់សម្គាល់យ៉ាងនេះក្តី ការសិក្សារបស់ក្រុមប្រឹក្សាពុំបានពិនិត្យមើលថា តើការអភិវឌ្ឍថាមពលវារីអគ្គិសនី និងការអភិវឌ្ឍធនធានទឹកនានា នឹងជះឥទ្ធិពលដល់ស្ត្រី និងសមត្ថភាពស្ត្រីក្នុងការទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់សម្រាប់ក្រុមគ្រួសាររបស់ពួកគេកម្រិតណានោះទេ។ ការសិក្សារបស់ក្រុមប្រឹក្សាគ្រាន់តែផ្តល់អនុសាសន៍ឱ្យគណៈកម្មការទន្លេមេគង្គ ធ្វើការស៊ើបអង្កេតទៅលើបញ្ហាយេនឌ័រ ដើម្បីបំពេញទៅលើកង្វះខាតទិន្នន័យនេះ។

## មានអនុសាសន៍តិចតួចសំរាប់កាត់បន្ថយផលប៉ះពាល់លើជនជាតិដើមភាគតិច និងជនជាតិភាគតិច

ការសិក្សារបស់ក្រុមប្រឹក្សាបានផ្តល់ការណែនាំតិចតួច អំពីរបៀប វាយតម្លៃពិចារណា ចៀសវាងនិងកាត់បន្ថយផលប៉ះពាល់ជាក់លាក់ណាមួយ ទៅលើជនជាតិភាគតិច និងជនជាតិដើមភាគតិច ដែលងាយរងគ្រោះបំផុតដោយសារការអភិវឌ្ឍវារីអគ្គិសនីក្នុងអាងទន្លេមេគង្គ។ ជនជាតិភាគតិច និងជនជាតិដើមភាគតិច គឺជាក្រុមដែលបានកំពុងទទួលរងគ្រោះដ៏ធ្ងន់ធ្ងរ ដោយសារភាពក្រីក្រកម្រិតខ្ពស់ កង្វះហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ ការថែទាំសុខភាព ឱកាសសេដ្ឋកិច្ច និងការចូលរួមផ្នែកនយោបាយ។[33] ក្រៅពីនេះ ក្រុមពលរដ្ឋទាំងនេះពឹងផ្អែកយ៉ាងខ្លាំងលើធនធានធម្មជាតិសម្រាប់ចិញ្ចឹមជីវិត ពីព្រោះឱកាសការងារ និងឱកាសរកប្រាក់ចំណូលមានតិចតួចសម្រាប់ពួកគេ។[34] ជាលទ្ធផល ជនជាតិភាគតិច និងជនជាតិដើមភាគតិច នឹងទទួលរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារការបាត់បង់ធនធានជលផល និងត្រីសម្រាប់បរិភោគ។[35]

## ពុំមាននិតិវិធីសម្រាប់អនុវត្តអនុសាសន៍នៃការសិក្សានេះ

សេចក្តីថ្លែងការណ៍កិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គឆ្នាំ២០១៨ បានដាក់បញ្ចូលនូវសកម្មភាពអាទិភាព ដោយចាត់ទុកថា លទ្ធផលនៃការសិក្សារបស់ក្រុមប្រឹក្សាគឺជា "ឯកសារយោងសម្រាប់រៀបចំផែនការ និងអនុវត្តផែនការ សម្រាប់គម្រោងថ្នាក់ជាតិ និងគម្រោងនានា ព្រមទាំងសម្រាប់កិច្ចការពាក់ព័ន្ធនានារបស់គណៈកម្មការទន្លេមេគង្គ។"[36] ទោះជាយ៉ាងនេះក្តី

---

28 *ឯកសារយោងដូចខាងលើ*

29 *ការសិក្សារបស់ក្រុមប្រឹក្សា៖ លទ្ធផលសំខាន់ៗ ២០១៧ ទំព័រទី ៣*

30 *ឯកសារយោងដូចខាងលើ*

31 *ឯកសារយោងដូចខាងលើ*

32 *ការសិក្សារបស់ក្រុមប្រឹក្សា ២០១៧ ទំព័រទី ៣*

33 មូលនិធិអន្តរជាតិសំរាប់ការអភិវឌ្ឍន៍កសិកម្ម (IFAD) និងកតិកាសញ្ញាជនជាតិដើមភាគតិចអាស៊ី (AIPP), កំណត់សំគាល់បច្ចេកទេសជាតិស្តីពីបញ្ហាជនជាតិដើមភាគតិច៖ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, IFAD និង AIPP, ខែធ្នូ ឆ្នាំ២០១២ ទំព័រទី ៤

34 មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការគ្រប់គ្រងបរិស្ថាន (ICEM), ការវាយតម្លៃផ្នែកយុទ្ធសាស្ត្របរិស្ថាននៃថាមពលវារីអគ្គីសនីនៅតាមដងទន្លេមេគង្គ, ឆ្នាំ២០១០ ទំព័រទី ១១១

35 *ឯកសារយោងដូចខាងលើ ទំព័រទី ១០៦*

36 សូមមើល <https://www.mrcsummit.org/assets/previous-summits/3rd-summit/0d11506d00/Siem-Reap-Declaration_3rd-MRC-Summit-2018.pdf> ទំព័រទី ៤

រដ្ឋាភិបាលប្រទេសជាសមាជិកតំបន់ទន្លេមេគង្គ ពុំទាន់បានបង្ហាញពីរបៀបឬនិតិវិធីក្នុងការប្រើប្រាស់ការសិក្សានេះ សម្រាប់អនុវត្តនៅក្នុងដំណើរការពិគ្រោះយោបល់ជាមុន និងការសម្រេចចិត្តនានាអំពីទំនប់វារីអគ្គិសនីក្នុងអាងទន្លេមេគង្គនៅឡើយទេ។

ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅតំបន់អាងទន្លេមេគង្គក្រោម គឺអាស្រ័យលើធនធានធម្មជាតិដែលពួកគេមាន ខំថែរក្សាអភិរក្សនូវធនធានធម្មជាតិ និងជីវចម្រុះទាំងនោះ។ ជាពិសេសគឺ ដីដែលមានជីវជាតិល្អ ព្រៃជម្រាល ព្រៃតាមដងទន្លេ និងលំហូរទន្លេតាមរដូវកាល ដែលទ្រទ្រង់ដល់ការនេសាទទឹកសាបធំបំផុតមួយរបស់ពិភពលោក។ ផែនការទំនប់វារីអគ្គិសនីធំៗបច្ចុប្បន្នពិតជានឹងអាចកាត់បន្ថយលទ្ធភាពធន់ទ្រាំ បង្កើនភាពងាយរងគ្រោះ និងកាត់បន្ថយចិរភាព របស់បណ្តាប្រទេសសមាជិកនៃទន្លេមេគង្គក្រោម។

**មានជំរើសជំនួសនានាជាច្រើនដែលអាចឆ្លើយតបតម្រូវការថាមពលក្នុងតំបន់។ ឧទាហរណ៍៖ ការសិក្សាថ្មីៗបង្ហាញថា តម្លៃកសាងប្រព័ន្ធថាមពលព្រះអាទិត្យ និងបណ្តាញបញ្ជូនអគ្គិសនី (ពីភាគនិរតីនៃប្រទេសចិន ទៅកាន់ប្រទេសថៃ និងវៀតណាម) នឹងមានតម្លៃថោកជាងគម្រោងវារីអគ្គិសនីនៅលើតួមេទន្លេទៅទៀត។[37]**

ថ្វីបើការសិក្សារបស់ក្រុមប្រឹក្សាបានបង្ហាញពីផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ ដូចជាអសន្តិសុខស្បៀង ការខូចខាតប្រព័ន្ធអេកូឡូស៊ី និងការបាត់បង់និរន្តរភាពក្តី ក៏ប៉ុន្តែ ជាការគួរឱ្យភ្ញាក់ផ្អើល ការសិក្សានេះហាក់ដូចជាស្វាគមន៍ការសាងសង់បន្ថែមនូវគម្រោងវារីអគ្គិសនីនៅលើតួមេទន្លេ និងផ្តល់អនុសាសន៍អំពីការកេណ្ឌពន្ធលើប្រាក់ចំណេញពីថាមពលវារីអគ្គិសនី ដែលអ្នកវិនិយោគគម្រោងអាចនឹងមិនទទួលយកបានអំពីការកេណ្ឌពន្ធបន្ថែមនេះ។

**ហេតុអ្វីបានជាគម្រោងវារីអគ្គិសនីធំៗ នៅលើតួមេទន្លេមេគង្គ នៅតែមានបន្តដំណើរការសាងសង់? ហេតុអ្វីបានជារដ្ឋាភិបាលឡាវចេញសេចក្តីប្រកាសអំពីការអភិវឌ្ឍគម្រោងអគ្គិសនីប៉ាក់ឡាយ (Pak Lay) ក្រោយពីការចេញផ្សាយអំពីការសិក្សារបស់ក្រុមប្រឹក្សាបានតែប៉ុន្មានខែប៉ុណ្ណោះ?**

ការសិក្សារបស់ក្រុមប្រឹក្សាបានកត់សម្គាល់ថា ផលិតកម្មសរុបរបស់អាងទន្លេមេគង្គ គឺមានកម្រិតគ្រប់គ្រាន់ដើម្បីរក្សាសន្តិសុខស្បៀងអាហារបាន១០០%។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសសមាជិកនៃគណៈកម្មការទន្លេមេគង្គ ចាំបាច់នឹងត្រូវសហការ និងបង្កើតបណ្តាញចែកចាយដែលមានប្រសិទ្ធភាព ដើម្បីកាត់បន្ថយកង្វះអាហារបរិភោគ ដោយសារតែការប្រែប្រួលនៃប្រព័ន្ធអេកូឡូហ្ស៊ីទន្លេមេគង្គ។[38] រដ្ឋាភិបាលដែលជាសមាជិកទន្លេមេគង្គ ពុំបានបញ្ជាក់ពីរបៀបក្នុងការសម្រេចកិច្ចការនេះទេ។

ដោយសារភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ និងគុណវិបត្តិនានា ការសិក្សារបស់ក្រុមប្រឹក្សាបានផ្តល់អនុសាសន៍ថា រដ្ឋាភិបាលជាសមាជិកត្រូវពិចារណាយ៉ាងហ្មត់ចត់ អំពីជម្រើសជំនួស ថាមពលកកើតឡើងវិញ ដើម្បីជំនួសឱ្យទំនប់វារីអគ្គិសនីដែលបំផ្លិចបំផ្លាញទន្លេមេគង្គ។ ប៉ុន្តែ ការសិក្សាពុំបានផ្តល់ព័ត៌មានដល់រដ្ឋាភិបាលជាសមាជិកទន្លេមេគង្គ អំពី និតិវិធីក្នុងការសម្រេចឱ្យបាន អនុឡោមទៅតាមព័ត៌មានដែលបានរកឃើញនានា និងអនុសាសន៍ដែលបានផ្តល់ឱ្យ សំរាប់ដាក់បញ្ចូលនៅក្នុងការធ្វើសេចក្តីសំរេចចិត្ត។

## កង្វះការចូលរួមពីសាធារណៈ តម្លាភាព និងគណនេយ្យភាព

ទោះបីជាគម្រោងទំនប់វារីអគ្គិសនីមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសន្តិសុខស្បៀង និងជីវភាពប្រជាជនក្នុងតំបន់ក៏ដោយ ដំណើរការការធ្វើផែនការ និងការសម្រេចចិត្តបច្ចុប្បន្ន នៅមានកង្វះការចូលរួមពីសាធារណៈ តម្លាភាព និងគណនេយ្យភាព។ ពុំមានការផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយនូវព័ត៌មានអំពីគម្រោងទំនប់វារីអគ្គិសនីនៅលើតួមេទន្លេមេគង្គទេ ថ្វីបើមានសំណើម្តងហើយម្តងទៀតពីសហគមន៍ សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងបណ្តាប្រទេសនៅតាមខ្សែទឹកខាងក្រោមក៏ដោយ។ ពុំមានការគោរពការសន្យាថានឹងបង្ហាញព័ត៌មានជាសាធារណៈ ដូចជា ព័ត៌មានលម្អិតនៃការរចនាគម្រោង ការវាយតម្លៃទៅលើយន្តការកាត់បន្ថយផលប៉ះពាល់ ដូចជា ថាតើការបង្កើតផ្លូវសម្រាប់សំរួលការបម្លាស់ទីរបស់ត្រី អាចជួយការពារជីវិតត្រីក្នុងអាងទន្លេមេគង្គបានដែរឬទេ ហើយថាតើយន្តការផ្សេងទៀត អាចជួយកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលកើតមានលើប្រព័ន្ធអេកូឡូហ្ស៊ីរបស់ទន្លេដែរឬទេ។

## អនាគតប្រកបដោយចីរភាពសម្រាប់ទន្លេមេគង្គ?

មកដល់ពេលនេះ រដ្ឋាភិបាលនៃប្រទេសជាសមាជិកនៃគណៈកម្មការទន្លេមេគង្គបានធ្វើសេចក្តីសម្រេចលើគម្រោងថាមពលវារីអគ្គិសនី ដោយផ្អែកទៅតាមគម្រោងនីមួយៗដោយឡែកពីគ្នា ដោយខ្វះនូវការពិចារណាលើផលប៉ះពាល់រួមនៅក្នុងអាងទន្លេទាំងមូល។ ក្នុងការសម្រេចចិត្តលើគម្រោងអនាគត រដ្ឋាភិបាលដែលជាសមាជិកទន្លេមេគង្គក្រោម ត្រូវតែធានាថា ខ្លួនបានប្រើប្រាស់លទ្ធផលនៃការសិក្សារបស់ក្រុមប្រឹក្សា ដែលបានវាយតម្លៃអំពីផលប៉ះពាល់ជាបណ្តុំ និងគុណវិបត្តិនៃគម្រោងថាមពលវារីអគ្គិសនី ដាក់បញ្ចូលនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៃគម្រោង។

ការសិក្សារបស់ក្រុមប្រឹក្សាបានផ្តល់អនុសាសន៍សំខាន់មួយគឺ ការស្នើរឱ្យបណ្តាប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ពិចារណាពីបច្ចេកវិទ្យាថាមពលថ្មីៗ ដូចជាថាមពលព្រះអាទិត្យ និងថាមពលខ្យល់ ជាជម្រើសជំនួសឱ្យថាមពលវារីអគ្គិសនី។ ការសិក្សាទៅលើបច្ចេកវិទ្យានេះ រួមជាមួយវិធានការគ្រប់គ្រងតម្រូវការ និងយន្តការប្រសិទ្ធភាពថាមពល នឹង "ផ្តល់នូវទិដ្ឋភាពចម្បងអំពីទំនាក់ទំនងរវាង ការគ្រប់គ្រងធនធានទឹក ថាមពល និងសន្តិសុខស្បៀង នៅក្នុងអាងទន្លេមេគង្គក្រោម"។[39]

ភាគីពាក់ព័ន្ធទាំងអស់ត្រូវទទួលបានការចូលដែលមានអត្ថន័យ ក្នុងការធ្វើសេចក្តីសម្រេចអំពីការចរចា ដើម្បីសម្រេចបានជោគជ័យ និងទទួលបានដំណោះស្រាយដែលការពារធនធានបរិស្ថានរបស់ទន្លេមេគង្គ ក៏ដូចជាគាំទ្រដល់ជីវភាពរបស់សហគមន៍តាមដងទន្លេ និងសេដ្ឋកិច្ចជាតិ។

37 ទីភ្នាក់ងារថាមពលកកើតឡើងវិញអន្តរជាតិ (IRENA) តម្លៃចំណាយថាមពលជំនាន់ថ្មីក្នុងឆ្នាំ២០១៧ IRENA ទីក្រុងអាប៊ូដាប៊ី ឆ្នាំ ២០១៨ <http://www.irena.org/publications/2018/Jan/Renewable-power-generation-costs-in-2017>.

38 *ការសិក្សារបស់ក្រុមប្រឹក្សា ២០១៧ ទំព័រទី ៤*

39 *ការសិក្សារបស់ក្រុមប្រឹក្សា៖ លទ្ធផលសំខាន់ៗ ២០១៧ ទំព័រទី ៤*

INTERNATIONAL RIVERS
people • water • life

# ដ្យាក្រាម៖ តារាងពេលវេលានៃព្រឹត្តិការណ៍ពាក់ព័ន្ធ

ដ្យាក្រាមនេះបង្ហាញពីវឌ្ឍនភាពសំខាន់ៗនៃដំណើរការអភិវឌ្ឍទំនប់វារីអគ្គិសនីនានានៅលើតួមេនៃទន្លេមេគង្គ ដែលអាចផ្តល់ជាព័ត៌មានសម្រាប់ធ្វើការសម្រេចចិត្ត ជាពិសេស ការវាយតម្លៃសំខាន់ៗ ក៏ដូចជាសំណើព័ត៌មាន និងការសិក្សាបន្ថែមមុនពេលបន្តដំណើរការគម្រោងទៅមុខទៀត។ តារាងពេលវេលានេះ បង្ហាញឱ្យឃើញថា គម្រោងវារីអគ្គិសនីលើតួមេនៃទន្លេមេគង្គ ត្រូវបានគេជំរុញឱ្យមានដំណើរការទៅមុខ ជាច់ដោយឡែកពីគ្នា ដោយបានយកចិត្តទុកដាក់តិចតួចទៅលើកង្វល់សមូហភាពក្នុងតំបន់ និងផលប៉ះពាល់ជាបណ្តុំក្នុងអាងទន្លេទាំងមូល។

## 2010

**២០ តុលា ២០១០៖** គណៈកម្មការទន្លេមេគង្គផ្តួចផ្តើមដំណើរការពិគ្រោះយោបល់ជាមុនសម្រាប់ទំនប់សាយ៉ាប៊ូរី (Xayaburi)

**ចុងឆ្នាំ ២០១០៖** ការសាងសង់ទំនប់សាយ៉ាប៊ូរី (Xayaburi) ចាប់ផ្តើម។ នេះគឺជាគម្រោងទំនប់វារីអគ្គិសនីទី១ នៅលើតួមេទន្លេមេគង្គ។

**១៥ តុលា ២០១០៖** គណៈកម្មការទន្លេមេគង្គបោះផ្សាយឯកសារស្តីអំពី ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (SEA) ទៅលើទំនប់វារីអគ្គិសនីនៅលើតួមេទន្លេមេគង្គ ដោយផ្តល់ជាអនុសាសន៍ឱ្យផ្អាកការសាងសង់ក្នុងរយៈពេល១០ឆ្នាំ និងធ្វើការសិក្សាបន្ថែម។ ធនាគារពិភពលោកគាំទ្រទៅលើការវាយតម្លៃជាយុទ្ធសាស្ត្រនេះ និងបញ្ជាក់ថា ខ្លួននឹងមិនផ្តល់ហិរញ្ញប្បទានគាំទ្រទៅលើគម្រោងទំនប់នានាដែលស្ថិតនៅលើតួមេទន្លេមេគង្គឡើយ។

## 2011

**២២ មេសា ២០១១៖** ឡាវបិទដំណើរការពិគ្រោះយោបល់ជាមុនស្តីពីទំនប់សាយ៉ាប៊ូរី

**មេសា ២០១១៖** អ្នកជំនាញឯករាជ្យពិនិត្យឡើងវិញទៅលើការវាយតម្លៃផលប៉ះពាល់បរិស្ថានរបស់ទំនប់សាយ៉ាប៊ូរី និងបានរកឃើញថា ការវាយតម្លៃនេះមានកង្វះខាត និងមិនគ្រប់គ្រប់គ្រាន់តាមបទដ្ឋាន។

**៨ ធ្នូ ២០១១៖** រដ្ឋាភិបាលជាសមាជិកនៃគណៈកម្មការទន្លេមេគង្គយល់ព្រមរៀបចំធ្វើការសិក្សារបស់ក្រុមប្រឹក្សា ដោយសិក្សាទៅលើ ផលប៉ះពាល់ជាបណ្តុំទៅលើអាងទន្លេទាំងមូល។

## 2012

**១៧ កក្កដា ២០១២៖** ឡាវប្រកាសអំពីការរចនាឡើងវិញនូវទំនប់សាយ៉ាប៊ូរី

**៦ កក្កដា ២០១២៖** វៀតណាម និងកម្ពុជា ទាមទារឱ្យមានការផ្អាកទំនប់សាយ៉ាប៊ូរី ដោយរង់ចាំការសិក្សាបន្ថែម។

**៧ ធ្នូ ២០១២៖** រដ្ឋសភាជាតិឡាវ អនុម័តលើទំនប់សាយ៉ាប៊ូរី

**៧ សីហា ២០១២៖** អ្នកភូមិថៃដាក់ពាក្យបណ្តឹងទៅលើ ការអនុម័តការចុះកិច្ចព្រមព្រៀងទិញថាមពលពីទំនប់សាយ៉ាប៊ូរី ថាជាបទរំលោភបំពានសិទ្ធិរដ្ឋម្មនុញ្ញ។ បណ្តឹងនេះទាមទារឱ្យមានការវាយតម្លៃទៅលើផលប៉ះពាល់បរិស្ថានឆ្លងដែន។

## 2014

**២៥ កក្កដា ២០១៤៖** គណៈកម្មការទន្លេមេគង្គផ្តួចផ្តើមដំណើរការពិគ្រោះយោបល់ជាមុនសម្រាប់ទំនប់ដុនសាហុង (Don Sahong) ដែលជាគម្រោងទំនប់វារីអគ្គិសនីទី២ ស្ថិតនៅលើតួមេទន្លេមេគង្គ ។

**២៤ មិថុនា ២០១៤៖** តុលាការរដ្ឋបាលកំពូលរបស់ប្រទេសថៃ ទទួលយកបណ្តឹងឧទ្ធរណ៍អំពីទំនប់សាយ៉ាប៊ូរី។

## 2015

**២៤ មករា ២០១៥៖** ថ្វីបើមានការអំពាវនាវឱ្យមានការសិក្សាបន្ថែម និងពុំទាន់ឈានដល់កិច្ចព្រមព្រៀងក៏ដោយ ដំណើរការពិគ្រោះយោបល់ជាមុនស្តីពីទំនប់ដុនសាហុងត្រូវបានបញ្ចប់។

## 2016

**មករា ២០១៦៖** ចាប់ផ្តើមសាងសង់សំណង់ទំនប់វារីអគ្គិសនីដុនសាហុង។

**២០ ធ្នូ ២០១៦៖** គណៈកម្មការទន្លេមេគង្គផ្តួចផ្តើមដំណើរការពិគ្រោះយោបល់ជាមុន សម្រាប់ទំនប់វារីអគ្គិសនីប៉ាកបេង (Pak Beng) ដែលជាគម្រោងទំនប់វារីអគ្គិសនីទី៣ ស្ថិតនៅលើតួមេទន្លេមេគង្គ ។

## 2017

**១៩ មិថុនា ២០១៧៖** គណៈកម្មការទន្លេមេគង្គបញ្ចប់ដំណើរការពិគ្រោះយោបល់ជាមុន របស់ទំនប់វារីអគ្គិសនីប៉ាកបេង ថ្វីបើគេបានរកឃើញថាមានកម្សោយយ៉ាងច្រើននៅក្នុងការសិក្សាដែលបានបង្ហាញក៏ដោយ។ គេបានប្រកាសថានឹងរៀបចំកិច្ចព្រមព្រៀងរួមមួយដើម្បីដោះស្រាយកង្វល់ដែលបានលើកឡើង។

**៨ មិថុនា ២០១៧៖** អ្នកភូមិថៃដាក់ពាក្យប្តឹង អំពីការពិគ្រោះយោបល់មិនគ្រប់គ្រាន់ទៅលើផលប៉ះពាល់ឆ្លងដែននៃទំនប់វារីអគ្គិសនីប៉ាកបេង (Pak Beng)។

## 2018

**កុម្ភៈ ២០១៨៖** គណៈកម្មការទន្លេមេគង្គចេញផ្សាយលទ្ធផលនៃការសិក្សារបស់ក្រុមប្រឹក្សា ដែលរកឃើញថា ទំនប់វារីអគ្គិសនីដែលបានគ្រោងទុក បង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន និងសេដ្ឋកិច្ចក្នុងតំបន់ ក៏ដូចជាសន្តិសុខស្បៀងរបស់ប្រជាជនក្នុងមូលដ្ឋាន។

**៨ សីហា ២០១៨៖** គណៈកម្មការទន្លេមេគង្គផ្តួចផ្តើមដំណើរការពិគ្រោះយោបល់ជាមុន សម្រាប់ទំនប់វារីអគ្គិសនីប៉ាក់ឡាយ (Pak Lay) ដែលជាគម្រោងទំនប់វារីអគ្គិសនីទី៤ ស្ថិតនៅលើតួមេទន្លេមេគង្គ ។

**២៣ កក្កដា ២០១៨៖** ការបាក់ទំនប់វារីអគ្គិសនីរណប ស៊ីពាន ស៊ីណាមណយ (Xe-Pian Xe-Namnoy) បណ្តាលឱ្យមនុស្ស៤០នាក់ស្លាប់ និងរាប់ពាន់នាក់ចាកចេញពីទីលំនៅ។ ឡាវប្រកាសនូវការស៊ើបអង្កេតជាតិទៅលើគម្រោងទំនប់វារីអគ្គិសនីនានា និងផ្អាកការវិនិយោគនានាទៅគម្រោងថ្មីៗ។